**ព្រះរាជាណាចក្រ កម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល

តុលាការកំពូល
សំណុំរឿង រដ្ឋប្បវេណី
លេខ:៣៧ប្រ
ចុះថ្ងៃទី០៤ ខែកម្ភៈ ឆ្នាំ២០០៥
<u>សាលដីកា</u>
លេខ:៥៧
ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៦

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៦ ដោយមានសមាសភាពដូចតទៅ:

១-ឯកឧត្តម ............ ជាប្រធាន
២-លោក ................ ជាចៅក្រម
៣-លោក ................ ជាចៅក្រម
៤-លោក ................ ជាចៅក្រមរបាយការណ៍
៥-លោក ..................... ជាចៅក្រម

<u>ក្រឡាបញ្ជី</u>

-លោកស្រី .............

<u>តំណាងមហាអយ្យការ</u>

-ឯកឧត្តម ............... ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ៥៦ (ច) ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ ២០០៤ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៧៤៩ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍រវាង :

-ដើមចោទឈ្មោះលអ ភេទប្រុស អាយុ៤៤ឆ្នាំ ជាតិខ្មែរ ឈ្មោះបសវ ភេទប្រុស អាយុ៣៩ឆ្នាំ ឈ្មោះឡព ភេទស្រី អាយុ៣២ឆ្នាំ ឈ្មោះគសថ ភេទស្រី អាយុ៤៤ឆ្នាំ (ជាម្ចាស់បណ្តឹងសាទុក្ខ) មានទីលំនៅភូមិព្រះពន្លា សង្កាត់ព្រៃកជ្រា ខណ្ឌមានជ័យ ក្រុងភ្នំពេញ ។

-ចុងចម្លើយឈ្មោះសហ (ចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៤៣ឆ្នាំ ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃភូមិព្រះពន្លា សង្កាត់ព្រៃកប្រា ខណ្ឌមានជ័យ ក្រុងភ្នំពេញ ។

-មានមេធាវី លោក........... ជាតំណាង ។

<u>កម្មវត្ថុបណ្តឹង:</u>ប្តឹងសុំដីកាសម្រេចកិច្ចការប្រញាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ២៣០ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៤ របស់ឈ្មោះលអ ប្តឹងមិនសុខចិត្តពីសាលដីកាលេខ៥៦(ច) ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០០៤ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៣៧ប្រចុះថ្ងៃទី០៤ខែកុម្ភៈឆ្នាំ២០០៥របស់តុលាការកំពូល

-តាមបណ្តឹងសុំដីកាសម្រេចកិច្ចការប្រញាប់ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ របស់ឈ្មោះលអ បសវ ឡព គសថ ប្តឹងឃាត់ផ្ទះលេខ៥៩C ផ្ទះវ១១៥ សង្កាត់វាលវង់ ខណ្ឌ៧មករា ក្រុងភ្នំពេញ របស់ឈ្មោះសហ ដោយកាលពីម៉ោងប្រហែល៥ ទៀបភ្លឺថ្ងៃទី០៧ ខែមីនា ឆ្នាំ២០០៣ មាន អគ្គីភ័យមួយឆាបឆេះឡើងពីផ្ទះដាក់ជ័រដែលជាកម្មសិទ្ធិរបស់ឈ្មោះសហ ដែលស្ថិតនៅភូមិព្រះពន្លា សង្កាត់ព្រែកប្រា ខណ្ឌមានជ័យ ក្រុងភ្នំពេញ ហើយបានឆាបឆេះរាលដាលមកដល់ផ្ទះពួកខ្លួន បណ្តាលឱ្យ
ផ្ទះ និងសំភារៈលុយកាក់មួយចំនួនផងដែរ ។ ដូចនេះដើម្បីការពារផលប្រយោជន៍របស់ខ្លួនទាំងអស់គ្នាពួកខ្លួនសុំឃាត់ទុកនូវផ្ទះដែលបានរៀបរាប់ខាងលើទុកជាបណ្តោះអាសន្ន រង់ចាំតុលាការសម្រេចដល់ អង្គសេចក្តី ។

-បានឃើញដីកាសម្រេចកិច្ចការប្រញាប់លេខ០៦ប្រ*ឈ* ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៣ របស់ តុលាការក្រុមភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងសុំដីកាសំរេចកិច្ចការប្រញាប់ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ របស់ដើមចោទឈ្មោះលអ ប៊ូត សុវណ្ណ ត្បិច ពោ គសថ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិ ច្បាប់ ។

២-ហាមឃាត់ឈ្មោះសហ មិនឱ្យធ្វើការលក់ដូរ ដូល បញ្ចាំ ធ្វើអំណោយ ផ្ទេរសិទ្ធិ ខណ្ឌ៧មករា ក្រុងភ្នំពេញជាបណ្តោះអាសន្ន រង់ចាំតុលាការសម្រេចដល់អង្គសេចក្តីចប់ជាស្ថាពរ ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន៤.០០០រៀល គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង១.៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ២០០០រៀល ប្រាក់នេះកាត់យកពី ប្រាក់ដែលដើមចោទបានបង់ទុកជាស្រេច ។

៤-ដីកាសម្រេចនេះមានអានុភាពអនុវត្តភ្លាមៗ ទោះជាមានបណ្តឹងឧទ្ធរណ៍ក៏ដោយ ។

៥-ដីកាសម្រេចនេះជំនុំជំរះ ប្រកាសជាសាធារណៈចំពោះមុខគូភាគី សម្រេចបើកផ្លូវប្តឹង ឧទ្ធរណ៍ទៅតាមច្បាប់ ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ៣០(ឈ) ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៣ របស់លោកមេធាវី .......... ជាអ្នកតំណាងឱ្យឈ្មោះសហ ប្តឹងមិនសុខចិត្តនឹងដីកាសម្រេចកិច្ចការប្រញាប់លេខ០៦(ឈ)ចុះថ្ងៃ៣០ ខែមិថុនា ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចដីកាសម្រេចកិច្ចការប្រញាប់ទាំងមូល ។

-បានឃើញសាលដីការដ្ឋប្បវេណីលេខ៥៦(ច) ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៣ របស់លោកមេធាវី ពូធ ធារីទុកជាត្រឹមត្រូវតាមទំរង់នឹងគតិច្បាប់ ។

២-បដិសេធដីកាសម្រេចកិច្ចការប្រញាប់លេខ០៦ ប្រ(ឈ) ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញចោលជាអសារបង់ ។

៣-ហាមឃាត់មិនអោយឈ្មោះសហ ធ្វើការលក់ដូរ បញ្ចាំផ្ទេរកម្មសិទ្ធិនូវដីដែល ជាទីតាំងផ្ទះនេះ ស្ថិតនៅភូមិព្រះពន្លា សង្កាត់ព្រែកប្រា ខណ្ឌមានជ័យ ក្រុងភ្នំពេញ ជាបណ្ដោះអាសន្នសិន ទំរាំតុលាការសម្រេចរឿងអង្គសេចក្ដីចប់ជាស្ថាពរ ។

៤-កាត់យកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍១៣.០០០រៀល គឺពន្ធហ្នឹង និងពន្ធចុះ បញ្ជីក្ដី ២៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់ចំនួន៤៥០រៀល ចំណាយលើកិច្ចប្រគល់ដីកាកោះ៥.០០០ រៀល និងចំណាយលើអាដ្ឋាធរតុលាការចំនួន ៥.០០០រៀល ។

៥-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខដើមចោទ មេធាវីចុងចម្លើយ កំបាំងមុខចុងចម្លើយ បើកផ្លូវប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្ដឹងសាទុក្ខលេខ២៣០ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៤ របស់ឈ្មោះលអ ប្ដឹងមិនសុខចិត្តនឹងសាលដីកាលេខ៥៦(ច) ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០០៤ ត្រង់ចំណុចនៃសេចក្ដីសម្រេច ទាំងមូល ។

-បានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា៖ បណ្ដឹងសាទុក្ខរបស់ឈ្មោះលើអាង ស្ថិតក្នុងកំណត់ច្បាប់គប្បីលើកយកមកពិចារណា ។

-សាលាឧទ្ធរណ៍សម្រេចសេចក្ដីមកនេះ ពុំត្រឹមត្រូវទេ ។

សូមក្រុមប្រឹក្សាជំនុំជំរះសម្រេចតាមច្បាប់ ។

-បានស្ដាប់ចម្លើយរបស់ឈ្មោះលអ (ជាម្ចាស់បណ្ដឹងសាទុក្ខ) នៅពេលសវនាការថា៖ បានជា ខ្លួនប្ដឹងសាទុក្ខមកតុលាការកំពូលនេះ មកពីសាលាឧទ្ធរណ៍កាត់ក្ដីមិនត្រឹមត្រូវទេ ភ្លើងឆេះចេញពីផ្ទះស្លប ជ័រ ដែលជាផ្ទះរបស់ឈ្មោះសហ ជួលឲ្យអ្នករកស៊ីលក់ជ័រទឹកឈ្មោះនង វ៉េត ហេតុដូច្នេះហើយបាន ជាខ្លួនប្ដឹងពីឈ្មោះសហ នៅពេលនេះមានប្រជាជនជាច្រើនដឹងឮ និងធ្វើជាសាក្សីពេញភូមិ ។ ហើយ
ផ្ទះគឺផ្ទះពួកវៀតណាម ។
ខ្លួនសុំសំណូមពរសុំឲ្យលោកសហ សងថ្លៃខូចខាតទ្រព្យសម្បត្តិផ្ទះសម្បែងខ្ញុំមកវិញ ។

បានស្ដាប់ចម្លើយរបស់ឡត នៅពេលសវនាការថា៖ ខ្លួនសុំឲ្យតុលាការជួយរកយុត្តិធម៌ ឲ្យខ្លួនផង ព្រោះផ្ទះខ្លួនឆេះអស់រលីហើយ នៅសល់តែ១ចង្កេះទេ គ្មានយកបានរបស់ទ្រព្យអ្វីទេ សូម្បីតែសៀវភៅកូនរៀនក៏គ្មានដែរ ដោយបានអ្នកគ្រូ លោកគ្រូ និងមិត្តភ័ក្រជួយជាសៀវភៅ ខោ អាវ ដល់កូនខ្លួនសម្រាប់ទៅរៀន ។

សូមសំណូមពរសុំឲ្យតុលាការកំពូលសម្រេចឲ្យឈ្មោះសហសងលុយមកខ្លួនព្រោះខ្លួនជំពាក់គេច្រើនណាស់ ។

-បានស្តាច់ចម្លើយរបស់ឈ្មោះបសវ នៅពេលសវនាការថា ៖ ខ្លួនសុំប្តឹងអោយលោកសហ សងលុយមកខ្លួន ពីព្រោះផ្ទះរបស់ខ្លួនឆេះអស់គ្មានសល់អ្វីទេ មានតែសំបកខ្លួន ភ្លើងឆេះនេះផ្តើម ចេញពីផ្ទះរបស់ឈ្មោះសហ ដែលជួលឱ្យគេស្តុបជ័រទឹក ។

-បានស្តាប់សចក្តីសន្និដ្ឋានរបស់មេធាវីតំណាងឱ្យចុងចម្លើយឈ្មោះសហ នៅពេលសវនាការ ថា៖ ផ្ទះឆេះនេះ គឺជាផ្ទះរបស់កូនក្តីខ្លួនជួលទៅឲ្យឈ្មោះនង សារ៉េត ចំណែកផ្ទះលេខ៥៩C គឺជាផ្ទះ របស់កូនក្តីខ្លួនស្នាក់នៅ គួរដើមចោទប្តឹងឃាត់ផ្ទះនៅទីតាំងនេះមិនគួរឃាត់ផ្ទះស្នាក់នៅទេ ហើយដើមចោទនាំគ្នាប្តឹងឃាត់ផ្ទះលោកនង សារ៉េត ទើបត្រឹមត្រូវ ។ ហើយតុលាការអង្គសេចក្តីមិនទាន់ដឹងថាកំហុសនេះធ្លាក់បន្ទុកទៅលើ សហ ឬ នង សារ៉េត ទេ សូមតុលាការពិចារណា ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមចោទសេចក្តីសន្និដ្ឋានរបស់មេធាវីនិងជាតំណាងចុងចម្លើយ ។

-ក្រោយពីបានពិភាក្សត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ២៣០ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៤ របស់លោកលី អេងធ្វើឡើងស្ថិតក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបាន ដោយយោងតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍យល់ឃើញថា ប្រភពនៃអគ្គីភ័យពុំមានភាពច្បាស់លាស់ថាចេញពីផ្ទះឈ្មោះ សហ ឬ ពីប្រភពផ្សេង ប៉ុន្តែបែរជាសម្រេចហាមឃាត់ការចាត់ចែងលើដីរបស់ ឈ្មោះសហវិញនោះជាការពុំត្រឹមត្រូវទេ ។

-យល់ឃើញថា ចុងចម្លើយលោកសហ បានអះអាងថា អគ្គីភ័យនេះកើតឡើងក្នុងផ្ទះរបស់ខ្លួនដែលជួលឲ្យឈ្មោះនង សារ៉េត ដូច្នេះលោកសហ មានចំណងកាតព្វកិច្ចជាប់ និងផ្ទះដែលជាកម្មសិទ្ធិរបស់ខ្លួនហើយ ។

-យល់ឃើញថា ការដែលលោកមេធាវី និងជាតំណាងឲ្យចុងចម្លើយលើកឡើងនាសវនាការ នេះថាគួរគប្បីដើមចោទប្តឹងទាមទារពីអ្នកជួលផ្ទះ កូនក្តីខ្លួននោះជាការពុំត្រឹមត្រូវទេ ពីព្រោះថាដោយរឿងនេះជារឿងមុនអង្គសេចក្តី ព្យសនៈកម្មមានហើយ ហើយអ្នកណាជាអ្នកទទួលខុសត្រូវជាការសម្រេច របស់រឿងនៃអង្គសេចក្តីនេះ ដូច្នេះម្ចាស់អចលនៈវត្ថុមាននតាតព្វកិច្ចបឋមក្នុងការទទួលខុសត្រូវរួម តាមគោលការនៃមាត្រា១២៨ នៃក្រិត្យច្បាប់លេខ៣៨ក្រច ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ។

-យល់ឃើញថា  វិធានការនេះមានលក្ខណៈបណ្តោះអាសន្ននៅឡើយទេ  ដូច្នេះការបះពាល់ដល់សិទ្ធិរបស់ម្ចាស់អចលនវត្ថុក៏ពុំមានទំហំធំដែរ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៥៦(ច) ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្តីមកនេះមានការខុសឆ្គងទាំងទម្រង់ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

## ចនិច្ឆ័យសេចក្តីចំពោះមុខដើមចោទ និងមេធាវីតំណាងចុងចម្លើយ

១-ទទួលបណ្តឹងសាទុក្ខលេខ២៣០ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៤ របស់ឈ្មោះលអ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៥៦(ច) ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ដោយឥតបង្វិល ។

៣-សម្រេចហាមឃាត់ឈ្មោះសហ  មិនឲ្យលក់ដូរ  បញ្ចាំធ្វើអំណោយផ្ទេរសិទ្ធិទៅអ្នកដទៃ  នូវផ្ទះលេខ៥៩Cផ្លូវ១១៥ សង្កាត់វាលវង់ ខណ្ឌ៧មករា ក្រុងភ្នំពេញ ជាបណ្តោះអាសន្ន រង់ចាំតុលាការ សម្រេចដល់អង្គសេចក្តីចប់ស្ពាពរ ។

៤-បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ៣៧ប្រ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០៥របស់តុលាការកំពូលទៅតុលាការក្រុងភ្នំពេញ ដើម្បីបញ្ចូលក្នុងរឿងនៃអង្គសេចក្តី ។

៥-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩០០០រៀលដែលដើមចោទបានបង់ គឺៈ -ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤.០០០រៀល  ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល  សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

-ចំណាយលើការប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩០០០រៀល ហើយតម្រូវឲ្យចុងចម្លើយសងប្រាក់ចំនួន១៩.០០០រៀល នេះទៅដើមចោទវិញ ។

៦-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៦ ។